NEWS RELEASE

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# ជំនាញការខាងសិទ្ធិមនុស្សរបស់ អ.ស.ប អំពាវនាវឲ្យមានតួនាទីស្នូលមួយសម្រាប់សង្គមស៊ីវិល ដើម្បីធានាគោលដៅអភិវឌ្ឍន៍ក្រោយឆ្នាំ២០១៥ ដែលមានការចូលរួម

ទីក្រុងហ្សឺណែវ (១៨ ឧសភា ២០១៥) - ជំនាញការមួយក្រុម* រាប់ពីស្ថាប័នដ៏ធំបំផុតរបស់ជំនាញការឯករាជ្យ នៅក្នុងប្រព័ន្ធសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ នៅថ្ងៃនេះ បានជំរុញឲ្យរដ្ឋសមាជិករបស់ អ.ស.ប ទទួលស្គាល់ និងឧបត្ថម្ភគាំទ្រដល់តួនាទីរបស់អង្គការសង្គមស៊ីវិលដែលមានសេរីភាព និងសកម្ម ក្នុងការអនុវត្តនូវរបៀបវារៈអភិវឌ្ឍន៍ក្រោយឆ្នាំ២០១៥។ ក្រុមជំនាញការទាំងនោះបានមានប្រសាសន៍ថា "តួនាទីស្នូលសម្រាប់សង្គមស៊ីវិលគឺជាវិធីតែមួយគត់ដើម្បីធានាឲ្យបានគោលដៅអភិវឌ្ឍន៍ក្រោយឆ្នាំ២០១៥ ដែលមានការចូលរួម"។

នៅក្នុងសេចក្ដីថ្លែងការណ៍រួមមួយ* ដែលបានចេញផ្សាយនៅថ្ងៃនេះ នៅពេលដែលតំណាងនានារបស់រដ្ឋាភិបាលជួបប្រជុំគ្នានៅទីក្រុងញូវយ៉កចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២២ ខែឧសភា ដើម្បីពិភាក្សាពីក្របខណ្ឌឃ្លាំមើល និងពិនិត្យឡើងវិញនៃរបៀបវារៈអភិវឌ្ឍន៍ក្រោយឆ្នាំ២០១៥ ក្រុមជំនាញការបានអំពាវនាវឲ្យគោលដៅសកលថ្មីនេះអាចចាក់ឫសរឹងមាំក្នុងនិយាម និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដោយសង្កត់ធ្ងន់ទៅលើគោលការណ៍នៃការចូលរួម។

ក្រុមជំនាញការបានកត់សម្គាល់ថា "លំហពលរដ្ឋនៅទូទាំងពិភពលោកកំពុងតែរួមតូច ដូច្នេះហើយ មានសេចក្ដីត្រូវការឲ្យទទួលស្គាល់ច្បាស់លាស់ពីសារៈសំខាន់របស់សង្គមស៊ីវិលដែលមិនមានការត្រួតត្រា ឬរិតត្បិត និងរស់រវើកមួយ"។ "សង្គមស៊ីវិលគឺជាផ្នែកចំបាច់ក្នុងការជួយឲ្យរដ្ឋាភិបាលស្វែងរកដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតចំពោះបញ្ហាអភិវឌ្ឍដែលមានលក្ខណៈស្មុគ្រស្មាញ ទន្ទឹមនឹងនោះដែរ ពួកគេជាញឹកញយជួយផ្ដល់សេវាសាធារណៈចាំបាច់នានាផងដែរ"។

ក្រុមជំនាញការបានគូសបញ្ជាក់ថា "សង្គមស៊ីវិលដ៏រស់រវើកមួយក៏ធានាផងដែរថាសំឡេងរបស់ជនងាយរងគ្រោះ និងជនបាត់បង់ឱកាស ត្រូវបានរាប់បញ្ចូលប្រកបដោយអត្ថន័យទៅក្នុងគំនិតផ្ដួចផ្ដើមអភិវឌ្ឍដែលនឹងប៉ះពាល់ដល់សេចក្ដីប្រាថ្នា និងសុខុមាលភាពរបស់ពួកគេ"។ "ប៉ុន្តែដើម្បីបំពេញតួនាទីនេះ សង្គមស៊ីវិលត្រូវតែធ្វើប្រតិបត្តិការដោយមិនមានការត្រួតត្រា ឬរិតត្បិតឡើយ"។

ក្រុមជំនាញការខាងសិទ្ធិមនុស្ស បានប្រាប់ឲ្យដឹងពីការកើនឡើងគួរឲ្យព្រួយបារម្ភនូវការវាយប្រហារលើតួអង្គសង្គមស៊ីវិល ការរីកសាយនៃច្បាប់ដែលដាក់កម្រិតលើសេរីភាពនៃការសម្តែងមតិ ការបង្កើតសមាគម និងការជួបប្រជុំដោយសន្តិវិធី ការកើនឡើងនូវការរឹតត្បិតលើសម្ថភាពរបស់សមាគមក្នុងការទទួលបានធនធាននានា ការកើនឡើងនូវការយាយីរំខានបែបការិយាធិបតេយ្យដល់សង្គមស៊ីវិល ការធ្វើទុកបុកម្នេញដោយសារបុព្វហេតុនយោបាយមកលើអ្នកការពារសិទ្ធិមនុស្ស ការបំបែកដោយប្រើអំពើហិង្សាលើការធ្វើបាតុកម្មដោយសន្តិវិធី និងការកើនឡើងខ្លាំងយ៉ាងឆាប់រហ័យនូវការឈ្លបយកការណ៍ដោយខុសច្បាប់លើសកម្មជននានា។

ក្រុមជំនាញការក៏បានសម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងផងដែរលើការកើនឡើងយ៉ាងឆាប់រហ័យនូវចំនួននៃរបាយការណ៍ដែលចងក្រងជាឯកសាលើការបំពារបំពានលើរាងកាយ និងការសម្លាប់ ជាពិសេស អ្នកការពារបរិស្ថាន បុគ្គលិកសង្គមកិច្ច សកម្មជនសិទ្ធិស្ត្រី និងសមាជិកផ្សេងទៀតរបស់សង្គមស៊ីវិលដែលបំពេញការងារលើកស្ទួយការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។

ក្រុមជំនាញការបានមានប្រសាសន៍ថា "វាគឺជាប្រការចាំបាច់ដែលថា គោលការណ៍នៃភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល ក៏ដូចជា លំហសម្រាប់សង្គមស៊ីវិលដើម្បីអាចធ្វើប្រតិបត្តិការដោយមិនមានការត្រួតត្រា ឬរិតត្បិត នោះគឺជាបេះដូង ឬជាស្នូលនៃក្របខ័ណ្ឌក្រោយឆ្នាំ២០១៥"។ "គោលដៅក្រោយឆ្នាំ២០១៥ ដែលបានចែករំលែក ក៏រាប់ថាជាផ្នែកសំខាន់ និងសន្មតជាមុនផងដែរនូវសមត្ថភាពរបស់សង្គមស៊ីវិល ក្នុងការប្រាស្រ័យទាក់ទង និងធ្វើកិច្ចសហប្រតិបត្តិការគ្នាដោយសេរី នៅទូទាំងពិភពលោក ដោយមិនមានឧបសគ្គណាមួយដែលរារាំងកិច្ចសហប្រតិបត្តិការផ្នែកហិរញ្ញវត្ថុ និងសម្ភាររបស់សង្គមស៊ីវិលឆ្លងដែន និងការជួយឧបត្ថម្ភគាំទ្រសម្រាប់សង្គមស៊ីវិលទាំងនោះឡើយ"។

ក្រុមជំនាញការខាងសិទ្ធិមនុស្សបានសង្កត់ធ្ងន់ថា រាល់អង្គការសង្គមស៊ីវិលទាំងអស់ ដោយមិនគិតពីឋានៈរបស់ពួកគេនៅថ្នាក់ជាតិ និងអន្តរជាតិនោះ គួរតែត្រូវបានចាត់ទុកថាជាដៃគូស្មើមុខស្មើមាត់ និងមានសិទ្ធិចូលរួម និងមានប្រសិទ្ធភាពទៅលើដំណើរការក្រោយឆ្នាំ២០១៥ ដោយផ្អែកលើមូលដ្ឋានសមភាព។

ក្រុមជំនាញការបានមានប្រសាសន៍ថា "ការសន្យាថាគ្មាននរណាម្នាក់ត្រូវបានទុកចោលមិនអើពើ មិនអាចបំពេញបានឡើយ ប្រសិនបើជាមិនមានការចូលរួមរបស់សង្គមស៊ីវិលយ៉ាងពេញលេញ និងមិនមានការត្រួតត្រា ឬរិតត្បិតនៅពេញដំណើរការក្រោយឆ្នាំ២០១៥ រាប់ចាប់ពី កិច្ចចរចារអំពីទិសដៅ គោលដៅ និងសូចនាករ រហូតដល់ ការឃ្លាំមើល និងពិនិត្យឡើងវិញនូវវិធានការដើម្បីសម្រេចបាននូវទិសដៅ គោលដៅ និងសូចនាករទាំងនោះ"។

ក្រុមជំនាញការបានសន្និដ្ឋានថា "ការចូលរួមជាសាធារណៈក្នុងកិច្ចការអភិវឌ្ឍន៍ និងគណនេយ្យភាព នឹងនៅតែមានភាពលំបាកដោយមិនមានសង្គមស៊ីវិលដ៏សកម្មមួយ ដែលកើតចេញពីស្ត្រី និងបុរស ទាំងក្មេងទាំងចាស់

ដែលត្រូវបានផ្តល់សិទ្ធិអំណាចឲ្យ ដែលអ្នកទាំងនោះអាចអនុវត្តសិទ្ធិរបស់ខ្លួនក្នុងបរិយាកាសមួយអំណោយផល ប្រកបដោយការគាំទ្រនោះ”។

(*) ដើម្បីអានសេចក្តីថ្លែងការណ៍ទាំងស្រុង និងបញ្ជីឈ្មោះជំនាញការផ្សេងៗ សូមចូលទៅកាន់៖ http://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=15970&LangID=E

## ចប់

ជំនាញការឯករាជ្យគឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញការឯករាជ្យនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ) គឺជាឈ្មោះទូទៅនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ ដែលលើកអំពីស្ថានភាពរបស់ប្រទេសមួយជាក់លាក់ ឬ**បញ្ហា**តាមវិស័យនីមួយៗនៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ អ្នកជំនាញការរបស់នីតិវិធីពិសេស ធ្វើការឈរលើគោលការស្ម័គ្រចិត្ត ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយក៏មិនទទួលប្រាក់បៀវត្សរ៍សម្រាប់ការងាររបស់ពួកគាត់ដែរ។ ពួកគាត់ធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ពួកគាត់។

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមទាក់ទងមក ៖*
*លោកស្រី ហ្វីឌីរីកា ដូណាទី (Ms. Federica Donati) តាមរយៈទូរស័ព្ទលេខ) +៤១ ២២ ៩១៧ ៩៤ ៩៦ អ៊ីម៉េល / fdonati@ohchr.org)*

សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖
សាប៊ៀរ សេលាយ៉ា (Xabier Celaya) អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ អ៊ីម៉េល / *xcelaya@ohchr.org(*

**សិទ្ធិមនុស្ស អប ស្វែងយល់ពីយើង.ស.លើបណ្តាញព័ត៌មានសង្គម ៖**

**ហ្វេសប៊ុក៖** https://www.facebook.com/unitednationshumanrights និង https://www.facebook.com/OHCHRCambodia

**ទ្វីតធឺ៖** http://twitter.com/UNrightswire និង http://twitter.com/OHCHR_Cambodia

**ហ្គោហ្គីល៖ Google+** gplus.to/unitednationshumanrights

**យូធូប៖** http://www.youtube.com/UNOHCHR

**បរិយាយសាច់រឿង ៖** http://storify.com/UNrightswire

ផែកលិបិក្រមសិទ្ធិមនុស្សជាសកល ៖ http://uhri.ohchr.org/en